ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តពោធិ៍សាត់

សាលក្រមព្រហ្មទណ្ឌ (ជាស់មុខ)
-លេខ: ០៨ "ខ"
-ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០២៣
-សំណុំរឿងព្រហ្មទណ្ឌលេខ: ៨១៣
-ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១
-សំណុំរឿងស៊ើបសួរលេខ: ៨២២
-ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២១
-សំណុំរឿងជំនុំជម្រះលេខ: ២១៩
-ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២២

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តពោធិ៍សាត់

បានបើកសវនាការជាសាធារណៈនៅថ្ងៃទីប្រាំបី ខែធ្នូ ឆ្នាំពីរពាន់ម្ភៃពីរ វេលាម៉ោងប្រាំបី និងសូន្យ១ នាទីព្រឹក ដោយមានសមាសភាព៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តពោធិ៍សាត់

**តំណាងអយ្យការ**

ឯកឧត្តម [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តពោធិ៍សាត់

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តពោធិ៍សាត់

ដើម្បីជំនុំជម្រះលើបណ្តឹងទាស់ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២២ នឹងសាលក្រមព្រហ្មទណ្ឌលេខ ៤៣៩ "គ" ចុះថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តពោធិ៍សាត់ ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៨១៣ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តពោធិ៍សាត់ ដែលមានពិរុទ្ធជន ៖

-ឈ្មោះ [redacted] អាំងគីម ភេទប្រុស កើតឆ្នាំ ១៩៥២ ជនជាតិខ្មែរ មុខរបរមន្ត្រីចូលនិវត្តន៍ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ១៨អូរ ផ្លូវលេខ K4B ភូមិត្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ យៀក ពេញ មានកូន០២នាក់ ឪពុកឈ្មោះ [redacted] សំឡី (ស្លាប់) ម្តាយឈ្មោះ [redacted] អៀង (ស្លាប់) ។ (ក្រៅឃុំ)

-ដោយមានលោក [redacted] និង លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] អាំងគីម ។

<u>ជាប់ចោទពីបទ:</u> ក្លែងបន្លំ (ក្លែងស្នាមមេដៃ) និង បទប្រើប្រាស់លិខិតក្លែង ប្រព្រឹត្តនៅចំណុចភូមិត្រពាំងវែង ឃុំក្បាលត្រាច ស្រុកក្រគរ ខេត្តពោធិ៍សាត់ កាលពីអំឡុងឆ្នាំ២០០៥ រហូតដល់ឆ្នាំ ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា៦២៦, មាត្រា ៦២៧ និងមាត្រា ៦២៨ នៃក្រមព្រហ្មទណ្ឌ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាយ ហៅ [redacted] សាយ ភេទប្រុស អាយុ៦១ឆ្នាំ មុខរបរកសិករ មានទីលំនៅបច្ចុប្បន្ននៅភូមិឡូត៍ឡ សង្កាត់ព្រែកព្រះស្តេច ក្រុងបាត់ដំបង ខេត្តបាត់ដំបង

-ដោយមានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងឈ្មោះ [redacted] សាយ ហៅ [redacted] សាយ ។

## អង្គហេតុមានដូចតទៅ

កាលពីថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ២០២១ ឈ្មោះ [redacted] សាយ ហៅ [redacted] សាយ បានដាក់ពាក្យបណ្តឹងប្តឹងទាមទារដីនៅចំណុចភូមិត្រពាំងវែង ឃុំក្បាលត្រាច ស្រុកក្រគរ ខេត្តពោធិ៍សាត់ ពីឈ្មោះ [redacted] អាំងគីម មក



Scanned with CamScanner

សាលាដំបូងខេត្តពោធិ៍សាត់ នៅក្នុងនីតិវិធីរបស់សាលាដំបូងខេត្តពោធិ៍សាត់ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ តុលាការបានធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង បានបង្គាប់ឱ្យគូភាគីដាក់ភស្តុតាងមកតុលាការ ពេលនោះឈ្មោះ [redacted] អាំងគីម បានដាក់ភស្តុតាងជាឯកសារចំនួន០២ច្បាប់មានកិច្ចសន្យាផ្ទេរផ្តាច់នូវដីចំការស្វាយចន្ទី ចំនួន៧២ហិចតា ស្ថិតនៅភូមិត្រពាំងវែងញ ឃុំក្បាលត្រាច ស្រុកក្រគរ ខេត្តពោធិ៍សាត់ លេខ ៣៣៥ កត ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៥ និងសេចក្តីបញ្ជាក់នៃការផ្ទេរកម្មសិទ្ធចំការស្វាយចន្ទីលេខ ១០៧៧ កត ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩៦ ដែលមានស្នាមមេដៃរបស់ឈ្មោះ [redacted] សាយ និងនាង [redacted] សេង តែដាក់ស្តែងឈ្មោះ [redacted] សាយ ហៅ [redacted] សាយ និងប្រពន្ធឈ្មោះ [redacted] សេង មិនបានផ្តិតមេដៃផ្ទេរកម្មសិទ្ធិឱ្យទៅឈ្មោះ [redacted] អាំងគីម នោះទេ ពេលនោះទើបឈ្មោះ [redacted] សាយ ហៅ ប៊ុន សាយ បានដឹងថាឈ្មោះ [redacted] អាំងគីម បានក្លែងស្នាមមេដៃរបស់ខ្លួន និងប្រើប្រាស់លិខិតក្លែងនោះរហូតមកដល់បច្ចុប្បន្ននេះ ទើបជនរងគ្រោះ [redacted] សាយ ហៅ ប៊ុន សាយ បានដាក់ពាក្យបណ្តឹងប្តឹងឈ្មោះ [redacted] អាំងគីម មកអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់ ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ។

លុះនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ សាលាដំបូងខេត្តពោធិ៍សាត់បានបើកសវនាការជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៤១៣ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ២០២២ ដោយសម្រេចកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] អាំងគីម ដោយសម្រេចផ្តន្ទាទោសលើ៖

ឈ្មោះ [redacted] អាំងគីម ភេទប្រុស កើតឆ្នាំ១៩៥២ ដាក់ពន្ធនាគារកំណត់ ចំនួន០១ឆ្នាំ០៦ខែ(មួយឆ្នាំប្រាំមួយខែ) ពីបទ: ក្លែងបន្លំ (ក្លែងស្នាមមេដៃ) និង បទប្រើប្រាស់លិខិតក្លែង ប្រព្រឹត្តនៅចំណុចភូមិត្រពាំងវែងញ ឃុំក្បាលត្រាច ស្រុកក្រគរ ខេត្តពោធិ៍សាត់ កាលពីអំឡុងឆ្នាំ២០០៥ រហូតដល់ឆ្នាំ ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៦២៦, មាត្រា ៦២៧ និងមាត្រា ៦២៨ នៃក្រមព្រហ្មទណ្ឌ និង បង្គាប់ឱ្យឈ្មោះ [redacted] អាំងគីម សងសំណងទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាយ ហៅ [redacted] សាយ ចំនួន ២០,០០០,០០០ រៀល ការទាមទារលើសពីនេះត្រូវបដិសេធចោល ។

លុះរហូតមកដល់ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២២ ជនជាប់ចោទឈ្មោះ [redacted] អាំងគីម បានសុំប្តឹងទាស់នឹងសាលក្រមខាងលើតាមពាក្យបណ្តឹងទាស់របស់ខ្លួនមកសាលាដំបូងខេត្តពោធិ៍សាត់ ដើម្បីអោយតុលាការធ្វើការជំនុំជម្រះសារជាថ្មី។

## នាពេលសវនាការ

-ពិរុទ្ធជនឈ្មោះ [redacted] អាំងគីម បានឆ្លើយនាពេលសវនាការថា ខ្លួនពុំបានដឹងអំពីការកោះហៅរបស់តុលាការនៅនីតិវិធីសវនាការមុននោះទេ។ ខ្លួនបានដឹងពីបទចោទប្រកាន់របស់តុលាការហើយពីបទក្លែងស្នាមមេដៃ និងប្រើប្រាស់ឯកសារក្លែង ហើយខ្លួនពុំឯកភាពចំពោះសាលក្រមព្រហ្មទណ្ឌដែលសម្រេចផ្តន្ទាទោសខ្លួននោះទេ ។ ដោយហេតុថាកាលពីអំឡុងឆ្នាំ២០១៨ ឈ្មោះ [redacted] សាយ បានប្តឹងថាបាត់ប្លង់កម្មសិទ្ធិលេខ ៦៣០១៩៦ ហើយក្រោយមកនៅឆ្នាំ២០១៩ឈ្មោះ [redacted] សាយ បានប្តឹងខ្លួនដើម្បីទាមទារប្លង់ដីនេះ ដោយគាត់អះអាងថាគាត់បានយកទៅទុកនៅបងថ្លៃរបស់គាត់ ហើយគាត់អះអាងថាដីនោះគាត់ទិញតាំងពីឆ្នាំ១៩៩៤មក រួចខ្លួនបានស្នើសុំធ្វើកោសលវិច័យលើស្នាមមេដៃឆ្នាំ១៩៩៦ និងស្នាមមេដៃដែលគាត់ប្តឹងខ្លួន ដោយខ្លួនឃើញថាស្នាមមេដៃដែលបាន

ធ្វើឡើងនៅឆ្នាំ១៩៩២ ឬ ឆ្នាំ១៩៩៣ គឺការមើលមិនឃើញពុំដូចគ្នានឹងស្នាមមេដៃឆ្នាំ១៩៨៦ នោះទេ ព្រោះស្នាមមេដៃរបស់ឈ្មោះ [redacted] សាយ នៅក្នុងឯកសារឆ្នាំ១៩៩២ ស្នាមមេដៃមួយមានស្នាមរបួស រីឯស្នាមមេដៃនៅលើឯកសារឆ្នាំ១៩៨៦ បែរជាគ្មានស្នាមរបួស ដោយប្រហែលជាឈ្មោះ [redacted] សាយ ពុំបានទៅផ្តិតមេដៃធ្វើប្លង់ដីនោះទេ ហើយខ្លួនក៏ពុំបានដឹងថាឈ្មោះ [redacted] សាយ ទទួលបានប្លង់តាមរបៀបណានោះដែរ ។ ក្រោយមកក៏ឈ្មោះ [redacted] វិសាល បានទៅសុំសុរិយោដីធ្វើប្លង់ថ្មី តែខាងសុរិយោដីមិនព្រម ។ ខ្លួនពិតជាបានដាក់លិខិតចំនួនពីរច្បាប់ជាឯកសារភស្តុតាងចូលទៅក្នុងសំណុំរឿងរដ្ឋប្បវេណី ដោយឯកសារប័ណ្ណ ៦៣-០១៨៦ គឺឈ្មោះ [redacted] វិសាល បានយកមកឱ្យខ្លួននៅផ្ទះដើម្បីខ្ចីប្រាក់ ពេលឈ្មោះ [redacted] វិសាល យកប្លង់ទៅបញ្ចាំខ្លួនដើម្បីយកលុយ៥ម៉ឺនដុល្លារអាមេរិក ខ្លួនមានលិខិតប្រគល់ប្រាក់ឱ្យឈ្មោះ [redacted] វិសាល ដោយក្នុងលិខិតដែលឈ្មោះ [redacted] វិសាល យកមកនោះគឺមានស្នាមមេដៃរបស់ហើយ និងមានស្នាមមេដៃឈ្មោះ [redacted] សាយ រួចជាស្រេចផងដែរ ដោយខ្លួនមិនស្គាល់បុគ្គលដែលមានឈ្មោះក្នុងតារាងនោះទេ ។ ចំណែកឯលិខិតដែលធ្វើឡើងនៅឆ្នាំ២០០៥ គឺឈ្មោះ [redacted] តាំងលី ជាអ្នកយកមកឱ្យខ្លួន។ ក្រោយមករហូតដល់ឆ្នាំ២០០៥ ខ្លួនពុំបានឃើញឈ្មោះ [redacted] វិសាល យកលុយមកឱ្យខ្លួនសោះ ដូចនេះខ្លួនក៏បានធ្វើលិខិតផ្ទេរសិទ្ធិមួយឱ្យឈ្មោះ [redacted] តាំងលី ទៅប្តឹងទារលុយពីឈ្មោះ [redacted] វិសាល និងឈ្មោះ [redacted] គីមស៊ិត ។ ប្រហែលជាធ្លាប់ខ្លួនប្តឹងពួកគាត់ចាំគ្នាទៅធ្វើលិខិតផ្ទេរសិទ្ធិ ហើយឈ្មោះ [redacted] តាំងលី បានយកលិខិតនោះមកឱ្យខ្លួន ។ ការអះអាងរបស់ឈ្មោះ [redacted] គីមស៊ិត ដែលអះអាងថាក្នុងលិខិតនោះពុំទាន់មានស្នាមមេដៃនោះទេ ហើយថាខ្លួនជាអ្នកយកដោះស្រាយជាមួយម្ចាស់ដីនោះ គឺជាការអះអាងមិនត្រឹមត្រូវនោះទេ។ ខ្លួនពុំធ្លាប់បានទំនាក់ទំនងជាមួយឈ្មោះ [redacted] សាយ នោះទេ ។ នៅឆ្នាំ២០០៥ ឈ្មោះ [redacted] សាយ បានហៅខ្លួនទៅជួបនៅសាលាឃុំ តែខ្លួនមិនទៅជួបនោះទេ ។ ខ្លួនពុំធ្លាប់បានជួប ពុំស្គាល់មុខឈ្មោះ [redacted] សាយ នោះទេ ហើយក៏មិនបានឱ្យផ្តិតមេដៃអ្វីនោះដែរ ខ្លួនទើបស្គាល់ឈ្មោះ [redacted] សាយ នៅឆ្នាំ២០១៩ប៉ុណ្ណោះ ។ ពេលឈ្មោះ [redacted] តាំងលី យកឯកសារលិខិតដែលមានស្នាមមេដៃផ្ទេរសិទ្ធិរបស់កម្មសិទ្ធិករនោះគឺគាត់មកម្នាក់ឯងប៉ុណ្ណោះ។ ខ្លួនពុំបានដើរប្រមូលស្នាមមេដៃម្ចាស់កម្មសិទ្ធិករទាំងនោះទេ។ចំពោះលិខិតឆ្នាំ២០០៥ គឺឈ្មោះ [redacted] តាំងលី ជាអ្នកយកមកឱ្យខ្លួន ហើយចំពោះលិខិតឆ្នាំ២០០៥ នេះស្នាមមេដៃគឺមិនគ្រប់ដូចលិខិតឆ្នាំ១៩៨៦ នោះទេ ហើយលិខិតនោះគ្មានលេខនោះទេ។ ដើម្បីកាត់ប្លង់ដីបានគឺខ្លួនប្លង់កម្មសិទ្ធិផ្ទៀងផ្ទាត់ជាមួយពាក្យស្នើសុំ និងកំណត់វាស់វែងច្បាស់ត្រូវគ្នាហើយទើបខាងមន្ទីរសុរិយោដីគេធ្វើការកាត់ប្លង់កម្មសិទ្ធិជូនខ្លួន ហើយចំពោះការកាត់ប្លង់នោះគឺម្ចាស់ដើមជាអ្នកទៅផ្តិតមេដៃ ។ ដីទាំងនោះគឺខ្លួនបានលក់ខ្លះ និងបានឱ្យម្ចាស់ដើមទៅបញ្ចាំធនាគារក៏មាន។ ខ្លួនពុំធ្លាប់បានប្រើប្រាស់ឯកសារនោះទេ។ ចំពោះដីរបស់ឈ្មោះ [redacted] សាយ គឺមិនទាន់ផ្ទេរកម្មសិទ្ធិនោះទេ ។

## សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹង

តំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាយ ហៅ [redacted] សាយ ចំពោះការសួរដេញដោល និងការពិនិត្យលើភស្តុតាងកន្លងមក ក្នុងនាមជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹង សុំធ្វើកំណត់សម្គាល់មួយដូចជនជាប់ចោទបានលើកឡើងនៅក្នុងពេលសវនាការ ដោយឃើញថាដីទាំងអស់នេះគឺមានប័ណ្ណកម្មសិទ្ធិរៀងៗខ្លួន ហើយឈ្មោះ [redacted] វិសាល ក៏បានយកប្លង់ទាំងនោះទៅធនាគារខ្ចីប្រាក់ ប៉ុន្តែកូនក្តីខ្លួនគឺបានប្តឹងពីបទក្លែងបន្លំឯកសារសាធារណៈ ដោយហេតុថារាល់លិខិតផ្ទេរសិទ្ធិទាំងអស់ដែលឈ្មោះ [redacted] វិសាល បានយកទៅប្រើប្រាស់

ដើម្បីដាក់ធានាបំណុលឱ្យឈ្មោះ [redacted]អេងគីម ក៏ដូចជាឈ្មោះអ៊ុក អេងគីមបានយកទៅប្រើប្រាស់គឺមិនមែនជាផ្ទះរបស់កូនក្ដីខ្ញុំនោះទេ ហើយកូនក្ដីខ្ញុំក៏ពុំបានផ្តិតមេដៃប្រគល់សិទ្ធិនោះទេ ។ ដូចមានភ្ជាប់ក្នុងសំណុំរឿងស្រាប់គឺប័ណ្ណដីលេខ ៣៣៥ កត ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៥ និងប័ណ្ណលេខ១៧៧ កត ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩៦ ចំពោះប័ណ្ណឆ្នាំ២០០៥ គឺពុំមានស្នាមមេដៃរបស់កូនក្ដីខ្ញុំនោះទេ និងប័ណ្ណឆ្នាំ១៩៩៦ គឺមានស្នាមមេដៃ ប៉ុន្តែស្នាមមេដៃនេះក្រោយពីនីតិវិធីកោសលវិច័យត្រឹមត្រូវទៅ គឺពុំមែនជាស្នាមមេដៃរបស់កូនក្ដីខ្ញុំនោះទេ ប៉ុន្តែជនជាប់ចោទបានយកលិខិតប្រគល់សិទ្ធិឆ្នាំ១៩៩៦ នេះមកធ្វើការអះអាងថាជាស្នាមមេដៃរបស់កូនក្ដីខ្ញុំដើម្បីមានសិទ្ធិគ្រប់គ្រងទាត់ទែងដីរបស់កូនក្ដីខ្ញុំដែលមានទំហំ៥ហិកតា ។ ហេតុដូច្នេះឃើញថាទង្វើរបស់ជនជាប់ចោទខាងលើពិតជាបានប្រព្រឹត្តបទល្មើសក្លែងបន្លំប្រាកដមែន ហេតុដូច្នេះស្នើសុំឱ្យតុលាការតម្កល់សាលក្រមលេខ ៤៣៩ គ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២ ទុកជាបានការដដែល និងសុំសម្រេចបន្ថែមតាមមាត្រា ៣៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## សេចក្តីសន្និដ្ឋានស្នើសុំរបស់តំណាងអយ្យការ

បន្ទាប់ពីបានស្តាប់ការសួរដេញដោលនាពេលសវនាការរួចមក តំណាងអយ្យការនៅតែរក្សាបទចោទប្រកាន់ទុកជាបានការដដែល និងស្នើសុំទៅក្រុមជំនុំជម្រះតម្កល់សាលក្រមលេខ ៤៣៩ គ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២ ទុកជាបានការដដែល ។

## សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

តាមការសាកសួរដេញដោលនាពេលសវនាការ និងការបញ្ជាក់អង្គហេតុផ្សេងៗ រួចមកក្នុងនាមជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទខ្ញុំស្នើសុំឱ្យតុលាការស៊ើបសួរបញ្ជាក់ទៅលើឯកសារឆ្នាំ១៩៩៦ គឺគ្មានទំនាក់ទំនងគតិយុត្តិអ្វីជាមួយកូនក្ដីខ្ញុំនោះទេ ដោយឯកសារនេះគឺធ្វើឡើងរវាងគ្រួសារទាំង១៥ ជាមួយឈ្មោះ [redacted] វិសាល និងប្រពន្ធឈ្មោះ [redacted] គីមសិត ។ ទំនាក់ទំនងរវាងកូនក្ដីខ្ញុំ និងឈ្មោះ [redacted] វិសាល គឺកើតឡើងនៅក្នុងឆ្នាំ១៩៩៩ ពាក់ព័ន្ធនឹងការខ្ចីប្រាក់ប៉ុណ្ណោះ ។ ដូចនេះលិខិតក្លែងក្នុងឆ្នាំ១៩៩៦ គ្មានការពាក់ព័ន្ធអ្វីជាមួយកូនក្ដីខ្ញុំនោះទេ ហើយចំពោះកោសលវិច័យរបស់ក្រសួងមហាផ្ទៃដែលរកឃើញថាស្នាមមេដៃលើឯកសារឆ្នាំ១៩៩៦ គឺដូចគ្នាជាមួយស្នាមមេដៃរបស់ឈ្មោះ [redacted] សាយ ឬ [redacted] សាយ ដែលអះអាងថាជាមនុស្សតែម្នាក់ ហើយបើទោះបីជារកឃើញថាពុំមែនជាស្នាមមេដៃរបស់ឈ្មោះ [redacted] សាយក៏ដោយក៏គ្មានទំនាក់ទំនងជាមួយកូនក្ដីខ្ញុំដែរ ។ ទីពីរ ពាក់ព័ន្ធនឹងលិខិតចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៥ គឺជាឯកសារដែលបង្កើតឡើងដោយកូនក្ដីខ្ញុំពុំបានពាក់ព័ន្ធនឹងអំពើនេះនោះទេ គឺកូនក្ដីខ្ញុំបានទទួលឯកសារនេះពីឈ្មោះ [redacted] តាំងលី ដែលត្រូវបានកូនក្ដីខ្ញុំប្រគល់សិទ្ធិធ្វើជាតំណាងក្នុងការដោះស្រាយក្ដីនៅតុលាការ ប៉ុន្តែលោកអ៊ឹង តាំងលី បានយកលិខិតពាក្យបណ្ដឹងទៅបង្ហាញឈ្មោះ [redacted] វិសាល ហើយឈ្មោះ [redacted] វិសាល អាចនឹងមានការបារម្ភអំពីពាក្យបណ្ដឹងរបស់កូនក្ដីខ្ញុំ ទើបកើតចេញជាលិខិតពីរដាច់ដោយឡែកពីគ្នាគឺមួយជាលិខិតផ្ទេរសិទ្ធិដែលមានស្នាមមេដៃរបស់ឈ្មោះ [redacted] វិសាល និងឯកសារមួយទៀតដែលមានចន្លោះស្នាមមេដៃ គឺកូនក្ដីខ្ញុំអះអាងថាទទួលពីឈ្មោះ [redacted] តាំងលី គឺ មានសភាពដើមបែបនេះ ហើយក៏មិនដែលកែប្រែសភាពអ្វីទាំងអស់។ ពាក់ព័ន្ធឈ្មោះ [redacted] តាំងលី គឺកូនក្ដីខ្ញុំប្រគល់សិទ្ធិឱ្យដោះស្រាយនៅតុលាការមិនមែនសម្របសម្រួលដើម្បីបានលិខិតស្នាមមេដៃនោះទេ ។ ពេលទទួលបានលិខិតនេះគឺកូនក្ដីខ្ញុំបានរក្សាទុករហូតមក ដូចនេះស្នាមមេដៃនេះបង្កើតឡើងដោយវិធីណាគឺកូនក្ដីខ្ញុំពុំបានដឹងនោះទេ ។ ហើយ



Scanned with CamScanner

លិខិតនោះគឺប្រជាពលរដ្ឋជាអ្នកស្នើក្រមិត្តឱ្យឈ្មោះ [redacted] វិសាល ។ ពាក់ព័ន្ធនឹងការឆ្លើយរបស់សាក្សីឈ្មោះ [redacted] គឹមសិត គឺមានលក្ខណៈមិនស៊ីសង្វាក់គ្នាទៅនឹងចម្លើយនៅក្នុងសំណុំរឿងផ្សេងៗ ។ ក្នុងសំណុំរឿងរក្សាការពារឈ្មោះ [redacted] គឹមសិត បានឆ្លើយថាខ្លួន និងឈ្មោះ [redacted] វិសាល ពិតជាបានយកប្លង់ទៅដាក់បញ្ចាំឱ្យលោក [redacted] អាំងគីម ប្រាកដមែន ។ ហេតុដូច្នេះខ្លួនស្នើសុំតុលាការសម្រេចចេញសាលក្រមចាត់របៀប ដើម្បីធ្វើការស៊ើបអង្កេតលើសំណុំរឿងឡើងវិញ ដោយធ្វើកោសល្យវិច័យលើស្នាមមេដៃសំខាន់ៗរួមមានស្នាមមេដៃដែលផ្តិតលើពាក្យសុំកាន់កាប់ដីធ្លីឆ្នាំ១៩៩២ និងរបាយការណ៍អង្កេត ព្រោះឯកសារទាំងពីរនេះគឺមានស្នាមមេដៃឈ្មោះ [redacted] សាយ ដោយយកស្នាមមេដៃនេះជាគោលដើម្បីប្រៀបធៀបជាមួយស្នាមមេដៃបច្ចុប្បន្ន ដើម្បីរកឱ្យឃើញពីទំនាក់ទំនងគតិយុត្តិនិងភ្នារព្រោះដោយសារសំណុំរឿងនេះមានការខ្វះនីតិវិធីច្រើន ដោយកូនក្តីខ្លួនពុំបានចូលមកឆ្លើយបំភ្លឺនៅដំណាក់កាលអយ្យការ និងចៅក្រមស៊ើបសួរ និងពេលសវនាការ ដើម្បីតតាំងនោះទេ។ ហេតុដូចនេះស្នើសុំឱ្យតុលាការចេញសាលក្រមចាត់របៀប។

<u>មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងធ្វើសេចក្តីបញ្ជាក់បន្ថែម</u>

ចំពោះការលើកឡើងរបស់មេធាវីការពារឱ្យជនជាប់ចោទក្នុងការស្នើសុំធ្វើកោសល្យវិច័យលើស្នាមមេដៃការស្នើសុំកាន់កាប់ ឃើញថានីតិវិធីស្នើសុំកាន់កាប់នេះត្រូវបានបញ្ចប់ហើយ ដូចនេះមិនមានពាក់ព័ន្ធនៅក្នុងសំណុំរឿងនោះទេ ហើយចំពោះលិខិតមួយចំនួនដែលមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទលើកឡើងថាពុំមានហេតុ និងទំនាក់ទំនងគតិយុត្តិនឹងការក្លែងស្នាមមេដៃ ប៉ុន្តែជនជាប់ចោទបានយកលិខិតឆ្នាំ១៩៩៦ និង ឆ្នាំ២០០៥ មកធ្វើការអះអាងក្នុងការទាមទារសិទ្ធិនិងទំនាក់ទំនងដីក្នុងសំណុំរឿងរដ្ឋប្បវេណី ។ ការប្រើប្រាស់សិទ្ធិរបស់គាត់នៅក្នុងនីតិវិធីរដ្ឋប្បវេណីនេះបញ្ជាក់ឱ្យឃើញថាការស្នាមមេដៃរបស់កូនក្តីខ្លួនត្រូវបានក្លែង ។

<u>មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្តីបញ្ជាក់តប</u>

ការក្លែងលិខិត និង ប្រើប្រាស់លិខិតក្លែងទាល់តែមានទំនាក់ទំនងបទល្មើសពីរជាមួយ លុះត្រាតែគាត់បានក្លែងលិខិតនោះប្រាកដមែន ហើយគាត់យកលិខិតនេះទៅប្រើប្រាស់ទើបអាចចោទប្រកាន់លើបទល្មើសនេះបាន។

## សំដីចុងក្រោយបង្អស់របស់ពិរុទ្ធជន

-ពិរុទ្ធជនឈ្មោះ [redacted] អាំងគីម បាននិយាយសំដីចុងក្រោយបង្អស់ថា: ខ្លួនស្នើសុំឱ្យតុលាការធ្វើកោសល្យវិច័យលើឯកសាររបស់ឈ្មោះ [redacted] សាយ នៅឆ្នាំ១៩៩២ និង ឆ្នាំ១៩៩៦ ថាជាស្នាមមេដៃគាត់ពិតប្រាកដ និងសំណូមពរដល់តុលាការលើកលែងចោទប្រកាន់មកលើរូបខ្លួនផង ។

-ក្រោយពីបានស្តាប់ការឆ្លើយរបស់ពិរុទ្ធជន

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យពិរុទ្ធជន

-ក្រោយពីបានស្តាប់សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់

## សំអាងហេតុ

១-បណ្តឹងទាស់នឹងសាលក្រមព្រហ្មទណ្ឌលេខ ៤៣៩ "គ" ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] អាំងគីម បានធ្វើឡើងត្រឹមត្រូវទៅតាមទម្រង់និងតតិច្បាប់ ដែលអាចឱ្យតុលាការលើកយកបណ្តឹងទាស់នេះមកវិនិច្ឆ័យនិងសម្រេចសេចក្តីសាជាថ្មីម្តងទៀតបាន ។

២ តាមសាលក្រមព្រហ្មទណ្ឌលេខ ៤៣៩ "គ" ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តពោធិ៍សាត់ដែលបានសម្រេចកំបាំងមុខជនជាប់ចោទថា៖

-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] អាំងគីម ភេទប្រុស កើតឆ្នាំ១៩៥២ ដាក់ពន្ធនាគារកំណត់០១ឆ្នាំ០៦ខែ(មួយឆ្នាំប្រាំមួយខែ) ពីបទ: ក្លែងបន្លំ (ក្លែងស្នាមមេដៃ) និង បទប្រើប្រាស់លិខិតក្លែង ប្រព្រឹត្តនៅចំណុចភូមិត្រពាំងវែងញ ឃុំក្បាលត្រាច ស្រុកក្រគរ ខេត្តពោធិ៍សាត់ កាលពីអំឡុងឆ្នាំ២០០៥ រហូតដល់ឆ្នាំ ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៦២៦, មាត្រា ៦២៧ និងមាត្រា ៦២៨ នៃក្រមព្រហ្មទណ្ឌ។

-បង្គាប់ឱ្យឈ្មោះ [redacted] អាំងគីម សងសំណងទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាយ ហៅ [redacted] សាយ ចំនួន ២០,០០០,០០០ រៀល ការទាមទារលើសពីនេះត្រូវបដិសេធចោល ។

-តាមចម្លើយរបស់ពិរុទ្ធជនឈ្មោះ [redacted] អាំងគីម ដែលបានលើកឡើងនាពេលសវនាការ ថា ខ្លួនពុំបានទទួលដំណឹងអំពីការកោះហៅរបស់តុលាការ ហើយខ្លួនពុំទទួលយកបទចោទប្រកាន់របស់តំណាងអយ្យការនោះឡើយព្រោះខ្លួនពុំបានប្រព្រឹត្តអំពើដូចការចោទប្រកាន់នោះទេ ។

យោងតាមចម្លើយនាពេលសវនាការខាងលើ និងការពិនិត្យភស្តុតាងនានាក្នុងសំណុំរឿង ក៏ដូចជាឯកសារភស្តុតាងថ្មីបន្ថែមដែលខាងពិរុទ្ធជនបានដាក់ចូលមកតុលាការរួចមក ឃើញថាឯកសារមួយចំនួនជាឯកសារដែលតុលាការមិនធ្លាប់បានទទួលពីមុនមកនៅក្នុងសំណុំរឿង ហើយការលើកឡើងរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ដែលស្នើសុំឱ្យតុលាការធ្វើកោសលវិច័យទៅលើឯកសារមួយចំនួនដើម្បីប្រៀបធៀបស្នាមមេដៃរបស់ឈ្មោះ [redacted] សាយ ដែលបានផ្តិតនៅលើឯកសារពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩២ និងកំណត់ហេតុអង្កេតដី ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៩៣ នៃប័ណ្ណលេខ83-0196 ធៀបជាមួយស្នាមមេដៃរបស់ឈ្មោះ [redacted] សាយ ឬ/និង [redacted] សាយ លើឯកសារឈ្មោះ [redacted] សាយ ផ្តិតលើឯកសារ សេចក្តីបញ្ជាក់នៃការផ្ទេរកម្មសិទ្ធិចំការស្វាយចន្ទី ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ១៩៩៦ និងលើឯកសារ កិច្ចសន្យាផ្ទេរផ្តាច់ចំការស្វាយចន្ទី ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៥ និងស្នាមមេដៃរបស់ឈ្មោះ [redacted] សាយ ដើមបណ្តឹងរដ្ឋប្បវេណី ផ្តិតលើឯកសារ កំណត់ហេតុស្តីពីការផ្តិតយកស្នាមក្រយៅដៃ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ និងការកោះហៅសាក្សីឈ្មោះ [redacted] វិសាល និងឈ្មោះ [redacted] អ៊ុមសិត់ និងឈ្មោះ [redacted] សុខា មកសាកសួរ។ ដូចនេះដើម្បីស្វែងរកយុត្តិធម៌ជូនភាគីទាំងសងខាង និងដើម្បីឱ្យមានភាពច្បាស់លាស់ក្នុងការសម្រេចសេចក្តី គប្បីតុលាការបង្វិលសំណុំរឿងនេះទៅចៅក្រមស៊ើបសួរដើម្បីធ្វើការស៊ើបសួរបញ្ជាក់បន្ថែមតាមការស្នើសុំរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

## ហេតុដូច្នេះវិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងទាស់នឹងសាលក្រមព្រហ្មទណ្ឌលេខ ៤៣៩ "គ" ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] វណ្ណា ទុកជាត្រឹមត្រូវទៅតាមទម្រង់ និងតតិច្បាប់។

ង-ចាត់ឲ្យបញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ ៩១៣ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តពោធិ៍សាត់ ទៅលោក [redacted] សារឿន ជាចៅក្រមនៃសាលាដំបូងខេត្តពោធិ៍សាត់ ដើម្បីធ្វើការស៊ើបសួរលើសំណុំរឿងព្រហ្មទណ្ឌខាងលើបន្ថែម។

សាលក្រមនេះជំនុំជម្រះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] អាំងគីម និងចាត់ទុកចំពោះមុខដើមបណ្ដឹងឈ្មោះ [redacted] សាយ ហៅ [redacted] សាយ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០២៣ ។

ទុកសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| | |
|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
| ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] |

---

| | |
|---|---|
| | បានចម្លងត្រឹមត្រូវតាមច្បាប់ដើម |
| បានឃើញ | ថ្ងៃអង្គារ ១២កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦ |
| **ចៅក្រមជំនុំជម្រះ** | ធ្វើនៅពោធិ៍សាត់, ថ្ងៃទី០៣ ខែមករា ឆ្នាំ២០២២ |
| | **ក្រឡាបញ្ជី** |
| [redacted] | [redacted] |



Scanned with CamScanner